BMI0033

# សម្ភាសន៍ជាមួយឈ្មោះ ជិន ណែត ភេទប្រុស អាយុ៥៨ឆ្នាំ
# មុខងារសម័យខ្មែរក្រហមៈ ដាំបន្លែ នៅក្រសួងការបរទេស
# រស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០
# សម្ភាសដោយ សោម ប៊ុនថន
# ០១:១៥:០៨
# ២១ទំព័រ

ប៊ុនថន ៖ ជីបូងខ្ញុំចង់សួរឈ្មោះ?

ណែត ៖ ខ្ញុំឈ្មោះ ជិន ណែត ។

ប៊ុនថន ៖ ពូអាយុប៉ុន្មាន?

ណែត ៖ ៥៨ ។

ប៊ុនថន ៖ តើពូមកនៅម៉ាឡៃឆ្នាំ១៩៧៩ ឬឆ្នាំណា?

ណែត ៖ ឆ្នាំ១៩៧៩ ។ មែនទែនឆ្នាំ១៩៧៩ ខ្ញុំនៅខ្សែម ។ ដែលទៅដល់ទេ!

ប៊ុនថន ៖ ខ្ញុំអត់ដែលទៅដល់ដែរ!

ណែត ៖ ខ្ញុំចេញមកពីភ្នំពេញមក ។ មិនយើង ខ្ញុំវាយបណ្តើរ ថយបណ្តើរ ។ កន្លែង គាកន, កន្លែង៣២ កន្លែងសាស្ត្រាយើងរាល់ថ្ងៃ ។ ពីខ្សែមមក សាស្ត្រាយើង ។ ដល់ឆ្នាំ៨០ ខ្ញុំមកដល់នេះ ។

ប៊ុនថន ៖ ពូមកដល់ជីបូង មានភូមិ មានផ្ទះប្រជាជនរស់នៅទេ?

ណែត ៖ មិនមានទេ ។ មានតែអ្នកដែលភៀសខ្លួនមក ជាកងទ័ពតែម្តង ។ កងទ័ព និងនារីដឹកជញ្ជូន និងប្រជាជនយើង ។

ប៊ុនថន ៖ តើនៅទីនោះជាព្រៃ ឬយ៉ាងណា?

ណែត ៖ និយាយរួមព្រៃ ។ ទូទៅគឺព្រៃខ្លា ព្រៃជីរ ។ ព្រៃឫស្សី ឬព្រៃដុង ។

ប៊ុនថន ៖ អត់មានផ្លូវទេ?

ណែត ៖ អត់ទេ ។

ប៊ុនថន ៖ តើមករស់នៅយ៉ាងម៉េច?

ណែត ៈ យើងមកដល់ ។ ធម្មតាកងទ័ព យើងមានចែកជាកងៗ អនុសេនាតូច អនុសេនាធំ ជាកងវរ ជាកងពល ។ ក្នុងមួយកងពល ៤៥០ យើងនេះ កាលពីជំនាន់នោះ ។ វាមានវរសេនាធំ វរសេនាតូច ។ ចឹងគេបំបែកគ្នាទៅតាមកង ។ គេចែកព្រំដី មួយកងពលទទួលខុសត្រូវពីត្រឹមណាដល់ត្រឹមណា ។ ពីភូមិបឹងបេងនេះ ឃុំបឹងបេងនេះ ទៅដល់បន្ទាយទីមួយទល់គ្នានឹងប៉ោយប៉ែតហ្នឹង គេហៅសមរភូមិកងពល៤៥០ ។ ហើយគេវាយទ័ពនៅតាមអូរព្រំដែននេះរហូត មួយមុខសញ្ញាកងពលហ្នឹង ។ គេវាយទ័ពអ៊ីចឹងហើយ អង្គភាពនីមួយៗដោះស្រាយជំរំដោយខ្លួនឯង ។ ខាងផ្នាក់ឈើ មេបញ្ជាហ្នឹង គេឲ្យកៅស៊ូតង់ និងអង្រឹងមកហឹកាំបិត ពូថៅអី យើងធ្វើជំរកដោយខ្លួនយើងទៅ ។ កាលនោះយើងសំបូរឈើ យើងកាប់ឈើធ្វើជាជំរំហើយ យើងប្រក់តង់កៅស៊ូ ។ យើងចងអង្រឹងដេកពីក្រោមដង្ហែរគ្នាតង់មួយអង្រឹងបួននៅតាមអូរបណ្ដោយព្រំដែនរហូត ។ អ៊ីចឹងនៅតំបន់នេះ ការបាត់បង់ទឹកដីអី តាំងពីខ្ញុំមកអត់ឃើញទេ ។ ខ្ញុំធ្លាប់នៅត្រង់ណាគឺនៅត្រង់ហ្នឹង ទឹកដីអត់មានបាត់ ។ ដាក់ស្តែងនៅក្នុងដែនទីយ៉ាងណា ខ្ញុំអត់ដឹងទេ តែដាក់ស្តែងការរស់នៅរបស់ប្រជាជនយើងយ៉ាងម៉េចគឺដីនៅអ៊ីចឹង ។ តែកាលពីមុនវាព្រៃ ឥឡូវវាវាល ។ ពីមុននៅកៅស៊ូតង់ ក្រោយមកបានមកផ្ទះស្បូវ ក្រោយពីផ្ទះស្បូវមក បានមកផ្ទះធំ ។ ហើយពីព្រៃដុង ព្រៃ ដីរី ព្រៃខ្លា មកមានផ្លូវថ្មើរជើង ផ្លូវរទេះ ហើយក្រោយមកមានផ្លូវឡាន រហូតមកដល់សព្វថ្ងៃនេះ ។

ប៊ុនថន ៈ តើស្បៀងអាហារបានមកពីណា បើសុទ្ធតែព្រៃ?

ណែត ៈ ស្បៀងអាហារធម្មតា ។ កាលយើងតស៊ូ កាលនោះវាស្របច្បាប់ ដោយមានអង្គការសហប្រជាជាតិទទួលស្គាល់ ។ យើងជារដ្ឋឯករាជ្យ អ៊ីចឹងជំនួយ អង្គការសហប្រជាជាតិគេជួយ ជាអង្ករ ជាស្បៀង ជាម្ហូបអាហារ ថ្នាំពេទ្យ មុង ភួយ ។ ជារួមទាក់ទងការថែទាំសុខភាព និងហូបចុកគេជួយ ។

ប៊ុនថន ៈ តើដំបូងគេហៅម៉ាឡៃតែម្ដងនៅតំបន់នេះ?

ណែត ៈ គេហៅម៉ាឡៃតែម្ដង ព្រោះតំបន់នេះវាមានភ្នំច្រើន ភ្នំខាងមុននោះ ។ ប៉ុនវាមានភ្នំធំមួយភ្នំមេនោះគឺ ភ្នំមេឡៃ ។ ក្នុងចំណោមភ្នំតូចៗច្រើននោះគឺ មានភ្នំមួយមេគេគឺភ្នំមេឡៃ ។ ក្រោយមកយើងកាឡៃពាក្យគេមកម៉ាឡៃ ។

ប៊ុនថន ៈ ម៉ាឡៃនេះហៅតាមអ្វី?

ណែត ៈ ហៅតាម ហ៊ុន សែន គាត់ហៅ ។ ហ៊ុន សែន ហៅតាមចំណុចដែនទី ។ នៅក្នុងដែនទីគេ

វក់តែលេខ ។

ប៊ុនថន : តើប្រវត្តិពីដើម យ៉ាងម៉េចបានជាគេដាក់ឈ្មោះម៉ាឡៃនេះ?

ណែត : ពូ ហ៊ុន សែន គាត់ហៅភ្នំមៃឡៃ នៅនោះវាមានកូនភ្នំតូចៗច្រើន ហើយអានេះមេគេ អ៊ីចឹងគេហៅមៃឡៃ ។

ប៊ុនថន : មកដល់ដំបូង ពូពូគេហៅដូច្នេះ?

ណែត : គេហៅអ៊ីចឹងតែម្តង គេហៅតាមចំណុចដែនទី ។

ប៊ុនថន : ចុះពីមុនមកម៉ាឡៃនៅក្នុងស្រុក ឬតំបន់ណា?

ណែត : អត់ដឹងទេ ។ ប៉ុន្តែពីមុនមកខ្ញុំដឹងថា ភ្នំម៉ាឡៃឋិតនៅក្នុងខេត្តបាត់ដំបង ។ កាលនោះខេត្តបន្ទាយមានជ័យអត់ទាន់បំបែក ។

ប៊ុនថន : ពូដឹងថានៅក្នុងស្រុកអី?

ណែត : កាលនោះ អត់មានស្រុកទេ ។ ដាយព្រំដែននេះ អត់ស្រុកទេ ។ ខាងខ្ញុំអស៊ូហៅតំបន់តែម្តង ។ តំបន់នោះលក្ខណៈវាទូលាយ វាទាន់ចូលក្នុងក្រិត្យរបស់រដ្ឋាភិបាលទទួលស្គាល់ទេ ព្រោះយើងនៅក្នុងព្រៃ ។ អ៊ីចឹងយើងហៅតំបន់ យើងហៅស្រុកក៏ហៅមិនកើតដែរ ព្រោះយើងនៅក្នុងព្រៃ ។ តំបន់នោះ គេហៅតំបន់១០៧ គឺភ្នំម៉ាឡៃ ហើយទៅពីនេះទៅគេហៅតំបន់សាស្តារនោះ គេហៅតំបន់៣៧ ឥឡូវវាទៅជាស្រុកសាស្តារ ស្រុកសំពៅលូន ។ ពីមុនគេហៅតំបន់ភ្នំដី លេខ៣៧ ឥឡូវទៅជាស្រុកសំពៅលូន ។

ប៊ុនថន : អ្នកភូមិខ្លះគេថាតំបន់នោះស្ថិតនៅក្នុងអូរជ្រៅ?

ណែត : ពីដើមមកគេថានៅស្រុកអូរជ្រៅ ត្រូវ ។

ប៊ុនថន : គាត់ថាទៅខាងនោះនៅស្រុកសេរីសោភណ្ឌ មកខាងនេះស្រុកអូរជ្រៅ នេះភូមិសាស្ត្រ ។

ណែត : ដូចជានៅស្រុកអូរជ្រៅ តែខេត្តដូចជានៅខេត្តបាត់ដំបង កាលជំនាន់នោះ ។

ប៊ុនថន : ចុះឃុំភូមិគេដាក់យ៉ាងម៉េចក្រោយពីមានម៉ាឡៃ?

ណែត : កាលនោះឃុំអត់មានទេ មានតែតំបន់ម៉ាឡៃ ។ ប៉ុន្តែភូមិមានខ្លះ ដែលគេហៅតាមចំណុចដែលកន្ទ័ពឈរជើង ។ ឧទាហរណ៍ កន្លែងដែលគេហៅថា ភូមិត្រសេកជ្រំ នៅជាប់ពីជំនាន់សង្គ្រាមមកដោយសារកងទ័ពទៅនៅកន្លែងហ្នឹងមានដើមត្រសេកច្រើន ហើយមកដល់យើងចូលរដ្ឋាភិបាលហើយ ឈ្មោះហ្នឹងនៅរក្សាទុកដដែល ។ មានភូមិទៀតហៅថាភូមិដំបូលរិល ជាប់ពីសង្គ្រាមមកដែរ ។ សព្វថ្ងៃក៏ហៅដំបូករិលដែរ គឺចូលក្នុងការទទួលស្គាល់របស់រដ្ឋាភិបាល ។

ប៊ុនថន ៖ យ៉ាងម៉េចបានដាក់ដំបូកវិល?

ណៃត ៖ កាលនៅសង្គ្រាមហ្នឹងមានដំបូកធំមួយ ហើយដំបូកធំនេះកងទ័ពគេធ្វើទ័ព្វជុំវិញដំបូក ។ វិល ជុំវិញដំបូកដើម្បីការពារគ្រាប់ផ្លោង គេគេចជុំវិញដំបូង អ៊ីចឹងគេហៅដំបូកវិល ។

ប៊ុនថន ៖ អ៊ីចឹងភូមិផ្សេងៗទៀតនៅជាប់ឈ្មោះទេ?

ណៃត ៖ មាន ដូចជា ភូមិបឹងបេង ក៏ជាប់ឈ្មោះដែរ ។ ពីមុនគេហៅភូមិបឹងបេង ប៉ុនឥឡូវគេហៅ ឃុំបឹងបេង ដោយសារនៅក្នុងឃុំបឹងបេងពីមុនយើងមានបឹងមួយកាលពីមកដល់ដំបូងឆ្នាំ ១៩៧៩ ហើយនៅមាត់បឹងសំបូរដោយដើមបេង ។ មាត់បឹងមានដើមបេងច្រើនណាស់ បានគេហៅកន្លែងហ្នឹងបឹងបេង គេយកចំណុចសម្គាល់ ។ ក្រោយមកបានក្លាយទៅជាភូមិ បឹងបេង ។ ដល់ក្រោយយើងចូលជាមួយរដ្ឋាភិបាល ភូមិបឹងបេងហ្នឹងបាត់ បានបង្កើតទៅ ជាឃុំវិញ ។ ឯភូមិក៏មានច្រើន ។ ភូមិដូចខ្ញុំជម្រាប់អ៊ីចឹង គឺដាក់ភូមិភាគច្រើន សម្គាល់ទៅ តាមលក្ខណៈភូមិសាស្រ្តរបស់ភូមិ ដូចជា ភូមិចំបក់ ក៏មានដើមចំបក់ ។ នៅបឹងមានដើម ចំបក់ធំមួយ អាកន្លែងហ្នឹងគេហៅភូមិចំបក់ទៅ ឯភូមិជ្រៃ មានដើមជ្រៃធំនៅត្រង់ហ្នឹងទៅ ក៏គេហៅភូមិជ្រៃដល់សព្វថ្ងៃនេះទៅ ។ ហើយដល់ភូមិអូរល្ហោ ក៏វាមានចំណុចនេះដែរ ។

ប៊ុនថន ៖ អ៊ីចឹងភូមិភាគច្រើនដាក់តាមលក្ខណៈភូមិសាស្រ្ត?

ណៃត ៖ បាទជាព្រៃ ហើយភាគច្រើនជាឈ្មោះភូមិដែលយើងបានរៀបចំដាក់កាលនៅជាសង្គ្រាម ។

ប៊ុនថន ៖ តំបន់តែមួយទេ?

ណៃត ៖ បាទ ។

ប៊ុនថន ៖ លោកមកនៅក្នុងព្រៃនេះ មានវាយគ្នាជាមួយកម្លាំងខាងក្នុងទេ?

ណៃត ៖ ជារួមតំបន់នេះជាកន្លែងកងទ័ព អ៊ីចឹងវាចៀសអត់ផុតទេការប្រយុទ្ធគ្នាអត់រួចទេ ។ ខាងក្នុង គេនៅជិតនេះដែរ ភ្នំម៉ាឡៃ វានៅ ហើយយើងនៅព្រំដែននេះ វាកៀកគ្នា ។

ប៊ុនថន ៖ ចុះកម្លាំងនោះដែលចូលមកដល់ព្រំដែន?

ណៃត ៖ ឆ្នាំ១៩៨៥ គេដេញកម្លាំងចូលដីថៃ ចូលនៅតាមជំរំតាង៉ុក ជំរំខាងអីដាង ជំរំសាយធូ ។ ឆ្នាំ១៩៨៥ គេវាយធំ ខាងអ្នកតស៊ូទប់អត់បាន ក៏ភៀសខ្លួនចូលទៅដីថៃ ។ អង្គការ អិន ជី អ អីគេទទួលយកទៅចិញ្ចឹមឲ្យបាយឲ្យទឹកអី ។

ប៊ុនថន ៖ មានបើកស្បៀងអាហារឲ្យទេ?

ណៃត ៖ បាទធម្មតា ។

ប៊ុនថន ៖ មានស្តាប់ទេខាងកម្លាំងតស៊ូ?

ណែត :	ពីឆ្នាំ១៩៧៩ ពេលកងទ័ពតស៊ូភៀសខ្លួនមកនៅព្រំដែន!

ប៊ុនថន :	បាទ ៗ

ណែត :	ស្លាប់ ហើយប្រសិនបើយើងចងក្រងឯកសារ ហើយបើមានរូបភាពពីគួរឲ្យអាណោចអធម ណាស់ ៗ ប៉ុនយើងអត់មានអីទុកជាភស្តុតាំង យើងនិយាយបានតែមាត់ទេ ៗ បានឃើញ នៅភ្នែក យើងនិយាយតែមាត់ យើងថតទុកជាភស្តុតាងយើងអត់មាន ៗ វាមិនគួរបើ និយាយ ដើរកន្ទួង ដឹងនរណាជួយនរណា អត់បាយកាលនោះ ៗ អង្គការសហប្រជាជាតិ គេមកអត់ទាន់ យើងរត់ពីនោះមក ពីខែបួបីខែបានអង្គការសហប្រជាជាតិគេជួយ គេផ្តល់ ស្បៀងមកទាន់ អីចឹងរយៈពេលហ្នឹងយើងមករស់នៅ អត់ថ្នាំសង្កូវ អត់ម្ហូបអាហារ អត់ អង្ករ ៗ អីចឹងជំងឺគ្រុនចាញ់វាវាតត្បាតខ្លាំង ស្លាប់ច្រើនណាស់?

ប៊ុនថន :	ភាគច្រើនស្លាប់ដោយអត់អាហារឬ?

ណែត :	ភាគច្រើនស្លាប់ដោយសារជំងឺគ្រុនចាញ់ អត់ថ្នាំសង្កូវ អត់អាហារម្យ៉ាងទៀត ៗ ប៉ុនអត់ អាហារក៏អត់ទៀត រួមផ្សំ ៗ

ប៊ុនថន :	ចុះលោកពូដែលឈឺទេ?

ណែត :	ឈឺ តែខ្ញុំស៊ាំហើយ ព្រោះធ្លាប់តស៊ូឆ្នាំ១៩៧៣-៧២ ៗ ខ្ញុំនៅក្នុងព្រៃរហូត ចឹងខ្ញុំស៊ាំនឹង ជំងឺគ្រុនចាញ់ តែយើងមកដល់នេះឈឺល្មម ប៉ុន្តែមិនដូចប្រជាជនដែលមិនធ្លាប់ឆ្លងកាត់ ៗ

ប៊ុនថន :	អ្នកដែលរត់មកនោះអ្នកភ្នំពេញ ប្រជាជនធម្មតា ឬអ្នកតាមខេត្ត?

ណែត :	អ្នកភ្នំពេញ និងអ្នកតាមខេត្ត នៅតាមសហករណ៍ក៏មកដែរ កម្មករច្រើនណាស់ ៗ

ប៊ុនថន :	ចម្រុះគ្នា?

ណែត :	បាទទាំងកងទ័ព ទាំងកម្មកររោងចក្រ ៗ ទាំងកងចល័តក្មេងៗអីមកទាំងអស់ ប្រជាជន អ្នក មានលទ្ធភាពមក ៗ រទេះគោ រទេះក្របី មករាប់ពាន់រាប់ម៉ឺនបរមក ៗ

ប៊ុនថន :	លោកពូតាមប៉ៃលិន ឬតាមស្វាយ?

ណែត :	ខាងខ្ញុំជាកងទ័ពគេចែកជាពីរផ្លូវ ខាងខ្ញុំចេញពីភ្នំពេញមក មកបាត់ដឹង ៗ យើងដកថយ បណ្តើរ យើងទប់បណ្តើរ មកបាត់ដឹង ៗ ដល់អមលាំង ចេញមកពោធិសាត់មក មកដល់ សំឡូតមក បានអស់ផ្លូវនៅនោះ យើងឡើងភ្នំ ៗ ដូចជា២០ថ្ងៃបានឆ្លងភ្នំនោះ ចុះមកបាន ដល់ប៉ៃលិន ៗ

ប៊ុនថន :	ពូមកមានកងរបស់ពូ?

ណែត ៖ មានកង ហើយចម្រុះគ្នាជាមួយប្រជាជន យើងការពារប្រជាជន។ ប្រជាជនច្រើនជាង កងទ័ព ហើយនៅតាមភ្នំហ្នឹង ហើយនៅតាមភ្នំនេះអស់ច្រើន ចុះគ្មាននរណាយកនរណា សែងគ្នា ចុះបើយើងអស់កម្លាំងដែរ។ កងទ័ពក៏អស់កម្លាំង ព្រោះអត់អីហូប ចោលតាម ផ្លូវច្រើនប្រជាជនឈឺ។ មកដល់ជិតព្រំដែននោះ ក៏ចោលច្រើនដែរ។ ដល់ព្រំដែនអត់ពេទ្យ អត់មានជីវំទៀត ប្រជាជនស្លាប់ច្រើន។

ប៊ុនថន ៖ មកដល់ដំបូងចូលទៅថៃបានទេ?

ណែត ៖ មកដល់ខាងទំនាក់ទំនងព្រំដែន ពួកខ្ញុំបានទាក់ទងថៃសុំដឹកចេញមកខ្មែរ។ ដឹកពីប៉ៃលិន បានឆ្លងមកចូលគំរៀងនេះវិញ។ ចូលតាមថៃ ដឹកពីក្រោយមក ដឹកចូលដីគេ បានចូលមក គំរៀងដីយើងវិញ បើយើងដើរកាត់វាឆ្ងាយ។

ប៊ុនថន ៖ តើគេអនុញ្ញាតឬ?

ណែត ៖ អនុញ្ញាត ឡានគេដឹកជញ្ជូនឲ្យ។ កាំភ្លើងគេទុកមួយដុំ គេដឹកផ្សេង គេមិនឲ្យយើងកាន់នៅ នឹងដៃចូលទៅដីគេទេ។ កាំភ្លើងគេយកពីយើងទៅដាក់ឡានមួយផ្សេងទៅ ហើយយើងជិះ ឡានមួយផ្សេងទៅ។ ពេលចូលមកដីយើង បានគេប្រគល់កាំភ្លើងឲ្យវិញ។

ប៊ុនថន ៖ ពូបន្តមកបានមកដល់...?

ណែត ៖ ចេះតែបំបែកជាកង១ ពង្រាយ១មក បានមកដល់ប៉ោយប៉ែត។

ប៊ុនថន ៖ តាមសំពៅ?

ណែត ៖ ហ្នឹងហើយ។

ប៊ុនថន ៖ ពូមកដល់ដំបូង មានមីនទេ?

ណែត ៖ មានមីនដែលកងទ័ពយើងដាក់ការពារព្រំដែនខាងលិចនៅជំនាន់៧៥-៧៩។ មានខ្លះៗដែរ ប៉ុន្តែមានតិចទេ មីនគេដាក់មានខ្សែ។ មានរណ្តៅចម្រូង មានចម្រូង មានខ្សែ។

ប៊ុនថន ៖ ដាក់ការពាព្រំដែន?

ណែត ៖ បាទ កងទ័ពគេដឹង។

ប៊ុនថន ៖ កម្លាំងមកទាំងអស់ ឬបំបែកយ៉ាងម៉េច?

ណែត ៖ កម្លាំងនោះបំបែកទៅតាមកងពល។ ឧបមាថា កងពលនៅប៉ៃលិនហ្នឹង កងពល អ៊ី ឈាន កងពលលេខប៉ុន្មាន ទទួលមុខសញ្ញាត្រឹមណា ត្រឹមស្ទឹងកុយ។ មកកងពលមួយទៀត កាលនោះកងពលបង ចៀម ចេញពីស្ទឹងកុយ ពីខ្មែរមកដល់អូរប្រយុទ្ធ នៅម្តុំភ្នំតាង៉ុក

នេះ ។ កងពលមួយទៀត ចាប់ពីភ្នំតាង៉ុក មកដល់បឹងបេង គឺកងពលរបស់ តាកន នី កន ធ្លាប់ស្គាល់ទេ ។

ប៊ុនថន : ធ្លាប់ឮឈ្មោះ!

ណៃត : ចាប់ពីបឹងបេងមករហូតដល់ប៉ោយប៉ែតគឺកងពល សុខ ភាព ។ ស្គាល់ សុខ ភាព ទេ ។

ប៊ុនថន : បាទស្គាល់!

ណៃត : គេបែកអ៊ីចឹង ។ ពង្រាយតានកងពល ហើយកងពលគេពង្រាយកម្លាំងគេទៅតាមវរសេនាធំ វរសេនាតូច ទៅវាចាប់ដៃគ្នាជាប់ ។

ប៊ុនថន : វាយគ្នាទៅវិញមកនោះ តើកម្លាំងខាងក្នុងនៅបានយូរទេ?

ណៃត : តាមខ្ញុំចាំ ដូចជានៅខែពីរ ថ្ងៃ១២ ឆ្នាំ១៩៨៥ គឺក្រោយពីរថ្ងៃដែលព្រះករុណាយាងមកសាតាំងនេះ ដើម្បីទទួលសាតាំងនេះពីឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូតប្រទេសជាមិត្ត ។ ក្រោយពីរថ្ងៃហ្នឹង គឺគេវាយបុកចូលមកតែម្តង ។ ព្រះអង្គយាងចេញបានពីរថ្ងៃ បុកចូលមក កម្លាំងគេចម្រុះ ។

ប៊ុនថន : មកដល់ព្រំដែន?

ណៃត : បាទ មកដល់ព្រំដែន ។ ធ្លាយចូលដីថៃប៉ុន្មានគីឡូទៀត ។

ប៊ុនថន : ពូទៅខាងក្នុង?

ណៃត : កាលនោះខ្ញុំមិនមែនជាកងទ័ពទេ ។ ខ្ញុំធ្វើកងទ័ពយូរហើយ ខ្ញុំឈប់ធ្វើកងទ័ពឆ្នាំ១៩៨០ ។ ខ្ញុំនៅមន្ទីរ ខ្ញុំនៅសរសេរ ជំនួយការិយាល័យ ។ ខ្ញុំជាប្រជាជនធម្មតា អ៊ីចឹងទៅ ខ្ញុំទៅនៅដីថៃ ។ កងទ័ពគេគេចនៅក្នុង ហើយយើងអត់កាំភ្លើងទៅក្រោយ ។

ប៊ុនថន : កងទ័ពខាងក្នុងវាយចូលដល់ថៃ ឬឈប់នៅត្រឹមអូរ?

ណៃត : ត្រឹមអូរ ។

ប៊ុនថន : តើខាងថៃមានដាក់ទ័ពពង្រាយចាំទប់ទេ?

ណៃត : គេត្រៀម គេខ្លាចខាងនោះចូលហួសទៅក្នុងដីគេ ។ តាមព្រំដែនគេលើកទង់ជាតិគេ ដោតឲ្យខាងនោះដឹងថាដីគេ ។

ប៊ុនថន : មានដែលវាយហួសចូលដល់ថៃទេ?

ណៃត : ខ្ញុំចាំមិនច្បាស់ដែរ ។ កាលនោះមានចាប់ប្រជាជនថៃ ទៅដាក់គុកនៅសៀមរាប១០ឆ្នាំ ។ ខ្ញុំមិនដឹងចាប់នៅត្រង់ណា ប៉ុន្តែប្រជាជនថៃថាចាប់នៅចំការដូងគាត់ ។ អ៊ីចឹងបានន័យថាខាងនោះចូលដល់ដីគេ ។

ប៊ុនថន ៖ តើកម្លាំងតស៊ូមានយកកាំភ្លើងទៅតាមទេ?

ណែត ៖ មួយប្រាវដំបូងទៅទាំងអស់ ហើយបានមេយើងប្រមូលដាក់មួយដុំ។ មនុស្សដាក់មួយដុំ អាវុធដាក់មួយដុំ មិនកាន់ប្រផេងប្រផាងនៅដីគេទេ។ ម្យ៉ាងគេមិនឲ្យកាន់ទេ គេខ្លាចសន្តិសុខប្រទេសគេដែរ។ មេយើងប្រមូលទុក ហើយបានរៀបចំកម្លាំង កងទ័ពណាកាំភ្លើងណាឲ្យអ្នកនោះកាន់ហើយ បានបញ្ជូនមកវិញ។ ចូលដល់ជ្រៅទៅទន្លេសាប ហើយខាងក្នុងវាមកនៅត្រង់នោះម្តង នៅតាមព្រំដែនតាមភូមិយើង។ ហើយយើងចូលទៅទន្លេ ទៅតាគង់នៅជិតស្វាយ ទៅនៅជាមួយប្រជាជន ទៅផុតកម្លាំងធំនៅនេះ។ យកលុយទៅទិញអង្ករប្រជាជនហូបនៅទន្លេ។

ប៊ុនថន ៖ តើកម្លាំងដាក់នៅទីនោះរហូត ឬដកចេញវិញ?

ណែត ៖ ដាក់៥ឆ្នាំ។ ដល់ឆ្នាំ៨៩ មើលខាងនោះទន់ដៃហើយ យើងដាក់មួយព្រឹបបានទាំងអស់ ទាំងប៉ៃលិន។ បានយកប្រជាជនចូលវិញ បានបោះទីតាំងនៅរហូត បានមានការប្រយុទ្ធខ្លាំង តែមិនដែលមកដល់នេះ គឺប្រយុទ្ធនៅខ្លាងរាប់ បន្ទាយទីមួយ ម៉ក់ហឺន។

ប៊ុនថន ៖ មិនដែលទីនេះទេ!

ណែត ៖ លែងដល់ហើយ គ្រាប់ផ្លោងបានត្រឹមខ្លាងរាប់។ បន្ទាយទី១ អស់ត្រឹមហ្នឹងហើយ។ គេផ្លោងពីពោធិបីដើម ពីប៉ោយប៉ែតមក ពីសាលាក្រហម ពីកូនដំរី បានត្រឹមហ្នឹង។

ប៊ុនថន ៖ អ៊ីចឹង ពេលចូលមកម្តងទៀតឆ្នាំ១៩៨៩ តើនៅទីនេះជាព្រៃ ឬមានផ្ទះ?

ណែត ៖ តាមនេះកើតភូមិ ព្រោះឆ្នាំ៨៥ កើតភូមិហើយ។ ឈើមានអារ ផ្ទះខ្លះមានកើតធំៗ ឈើអាស្អាតៗដែរ ប៉ុនអត់ទាន់មានប្រកសង្កសីទេ គ្រាន់តែប្រក់ស្លឹក ឬស្បូវប៉ុណ្ណោះ។ ដល់ពេលយើងចូលចុង៨៩-៩០ ផ្ទះដែលយើងសង់ពីមុនឆេះអស់ហើយ បានន័យថាភូមិហ្នឹងជាភូមិចាស់ យើងគ្រាន់តែមកនៅ ហើយធ្វើផ្ទះថ្មី វាវាលស្រាប់ហើយ។

ប៊ុនថន ៖ ប្រជាជនមកដល់រករបរអ្វីដែរ?

ណែត ៖ កាលមកដល់ដំបូងមិនទាន់រកអីទេ គ្រាន់តែរកមីន។ រកមីនរាប់ខែទំរាំបានប្តូរផ្ទះមួយៗ រាវមីនដោយខ្លួនឯង។ រាវមីនហើយ បានចាប់ផ្តើមសង់ផ្ទះតូចៗ ជាខ្ទម ដូចមានសេសសល់ផ្ទះមួយនេះ។ ផ្ទះនេះសេសសល់ពីសម័យចូលមកដំបូង វាមានក្តាឡាំងគ្រាប់។

ប៊ុនថន ៖ ផ្ទះពូ?

ណែត : អត់មែនទេ ។ ផ្ទះមេឡូក្នុយគាត់ ធ្វើពីក្តារឡាំង អាហ្នឹងចុងឆ្នាំ៨៩ ដើមឆ្នាំ៩០ ។ សល់មួយ ក្រៅពីនោះអត់នៅទេ ធ្វើថ្មីអស់ហើយ ។ អាខ្ទមហ្នឹង ប្រែក្លាយទៅជាផ្ទះធំៗអស់ហើយ ។

ប៊ុនថន : តើរាវមីន មានគ្រោះថ្នាក់ទេ?

ណែត : មានគ្រោះថ្នាក់ច្រើន ។ ខ្លះដាច់ជើង ខ្លះក៏ស្លាប់ ខ្លះពិការភ្នែក ។

ប៊ុនថន : តើផ្ទះលោកពូមានមីនទេ?

ណែត : មាន ។

ប៊ុនថន : ច្រើនគ្រាន់ទេ?

ណែត : មិនច្រើនទេ ។ បើផ្ទះនេះមានច្រើន មីនសូវៀត ។ ផ្ទះនេះគេដាក់ខ្សែ បណ្តោយ ។ ខាងខ្ញុំផុត ព្រោះវានៅកៀកសារតាំង ព្រោះផ្លូវនេះជាផ្លូវចាស់ អីចឹងវាដាក់ខាងនោះផ្លូវដើម្បីការពារមកពីលិច ហើយកម្លាំងវានៅត្រង់នេះ ។ ខាងនេះវាអត់សូវដាក់ទេ ខាងនេះផ្លូវចាស់ផ្លូវតាំងពីឆ្នាំ៨១-៨២ ព្រោះព្រះករុណាយាងមកមានផ្លូវនេះហើយ ផ្លូវលើកដោយដៃ ។

ប៊ុនថន : នរណារាវបានប៉ុន្មានយកដីប៉ុណ្ណោះឬ?

ណែត : បាទ ។ គេណាគេហ៊ានរាវបានដីធំ ក៏យកទៅ ។

ប៊ុនថន : ចោះដីចំការ និងដីធ្វើស្រែ?

ណែត : ដីចំការ វាទៅតាមសំណាង ។ អ្នកខ្លះក៏ចំព្រៃមីនទៅ អ្នកខ្លះក៏អត់ចំទៅ ប៉ុន្តែភាគច្រើនមិនសូវប៉ះទេ ។ ដីធំមែន ប៉ុន្តែមិនប៉ះមីនទេ ព្រោះគេដឹងចំណុចថា ទីតាំងនោះនៅត្រង់ណាហើយគេដាក់ការពារពីណាទៅណា អីចឹងគេគ្រោះព្រៃមិនសូវត្រូវទេ ។ ត្រូវខ្លាំង គ្រោះថ្នាក់ខ្លាំងគឺភូមិនេះតែម្តង ព្រោះវានៅជាប់នឹងអូរព្រំដែន ហើយមីនគេធ្វើរបង ។ គេធ្វើរបងនៅតាមអូរព្រំដែននេះហើយ ។ របងគេធ្វើដូចដូន ហើយមានលួស មកពីលិច ហើយខាងក្នុងនេះមីន ។ គេប្រក់ដូនតែម្តង ហើយមីននៅខាងក្នុង ។ បើយើងមកពីខាងលិចយើងកាត់លួសចូលមក បើថាឆ្លងមីននេះមកផុតហើយ ត្រូវកាត់លួសនេះមួយសារទៀតបានឆ្លងមកប៉ះមីននេះ ។ ដោះអាមីននេះទៀត បានកាត់លួសបានចូលក្នុងបាន ហើយបើសិនជាចូលមកដល់ហើយមានផ្ទុះ ពួកនេះបាញ់ទៅទៀត ពិបាកគេចណាស់ ។ យើងចូលមកដោះអាហ្នឹង ខ្លះគេហ៊ាន ដោះលក់អេតចាយ ។

ប៊ុនថន : មកដល់៨៩ យើងចាប់បានប៉ុន្មានយើងធ្វើចំការ?

ណែត ៖ ៨៩ មិនទាន់មានលទ្ធភាពធ្វើចំការទេ យើងរៀបចំភូមិ ដោយសារក្នុងភូមិមានមីនច្រើន ។ ឆ្នាំ១៩៩០ យើងចាប់ផ្តើមធ្វើចំការបន្តិចៗ ដោយសារថ្នាក់ដឹកនាំនេះបានប្រកាសពីគោលនយោបាយបណ្តើរៗ ។ គោលនយោបាយឈានទៅរកកិច្ចព្រមព្រៀង ហើយយើងត្រៀមទស្សនៈ គោលជំហរដូចថា ខ្លួនទុកខ្លួន កុំពឹងគេ កំពឹងថ្នាក់ដឹកនាំទៀត ព្រោះថ្នាក់ដឹកនាំដែលបានអីៗ យកជួយយើងទាំងអស់គ្នាដោយសារមានប្រទេសជាមិត្តដែលគេជួយ ។ អ៊ីចឹងបើយើងមានកិច្ចព្រមព្រៀង ប្រទេសជាមិត្តគេលែងជួយយើង យើងត្រូវគិតគូរខ្លួនឯង ។ អ៊ីចឹងចាប់ពីឆ្នាំ១៩៩០មក យើងចាប់ផ្តើមសង់លំនៅដ្ឋានហើយ ខ្លះបានទៅរកដីចំការបន្តិចៗ បណ្តើរ ។ មួយហិកតាក្នុងមួយគ្រួសារ ទៅតាមលទ្ធភាព ព្រោះកាលនោះយើងធ្វើដោយកម្លាំងសុទ្ធ ។ ក្នុងមួយគ្រួសារ កន្លះហិកតា មួយហិកតា ធ្វើក៏យ៉ាប់ដែរ ប្រើកម្លាំងសុទ្ធ ។

ប៊ុនថន ៖ តើរបបនៅតែមានខុត្តម្ភ?

ណែត ៖ នៅតែមានបន្តិចៗ រហូតដល់៩១ កិច្ចព្រមព្រៀងប៉ារីស ២៣ តុលា ១៩៩១ ។ តាំងពីនោះមកចាប់ផ្តើមស្រុតបន្តិចម្តងៗ រហូតដល់៩២ ។ ៩៣ ដាច់ បោះឆ្នោតហើយចប់ ។ ប្រឹងធ្វើចំការខ្លួនឯង ហើយទៅទប់នៅមុខទៀត ។ កងទ័ពលីកាំភ្លើងទៅមុខទៀត បើមិនទប់យើងអត់ដី ។ គេមក យើងអត់ដីនៅ ភូមិ ចំការ ។

ប៊ុនថន ៖ ប្រុសទៅប្រយុទ្ធ តើស្រីៗគាត់នៅបង្កបង្កើនផល?

ណែត ៖ ពេលនោះភាគច្រើនក្លាយទៅជាប្រពន្ធកងទ័ព ហើយនៅសល់បន្តិចបន្តួចក៏នៅសល់ជាអង្គភាព នៅដឹកជញ្ជូនគ្រាប់ លីគ្រាប់ទៅមុខ ។ នៅនារីខ្លះដែលមិនទាន់មានប្តី ការងាររបស់គាត់គឺជួយដឹកគ្រាប់ទៅមុខ ។

ប៊ុនថន ៖ តើនៅមានការប្រយុទ្ធគ្នា?

ណែត ៖ រហូតដល់៩៦ ។ រៀបចំសមាហរណកម្មជាមួយរដ្ឋាភិបាល ៩៦ ម៉ាឡៃក៏ស្ងាត់កាំភ្លើង ។ ៩៧-៩៨ រៀបរយ តែនៅតំបន់ផ្សេងៗទៀត ។ នៅតំបន់អន្លង់វែងនៅ ។

ប៊ុនថន ៖ តើមុនសមាហរណកម្មនិងក្រោយសមាហរណកម្មជីវភាពប្រជាជន និងភូមិឃុំផ្លាស់ប្តូរយ៉ាងម៉េច?

ណែត ៖ បើប្រៀបពេលដែលយើងមិនទាន់សមាហរណកម្ម ការរស់នៅរបស់ប្រជាជនយើងនៅស្រុកម៉ាឡៃ អត់ទាន់មានអីជាស្ថិរភាពទេ ។ សន្តិសុខ ក៏មិនធានា ហើយស្ថិរភាពថា ឲ្យនៅហ្នឹងនំ មិនភិតមិនភ័យ មិនព្រួយបារម្ភនឹងលើកកញ្ជើរដើរ និងស្ពាយបាឡូដើរ ។ បើ

ប្រៀបធៀបទៅវាខុសគ្នា ។ កាលមុនសមាហរណកម្ម យើងខំរកស៊ីមានបានមែន តែយើងអត់មានអីហ្នឹងន៎ទេ ។ មិនដឹងជាថ្ងៃណា ហើយយើងបាននៅទីនេះតទៅថ្ងៃមុខ ឬអត់ ព្រោះវានៅប្រយុទ្ធគ្នា ។ ក្រោយសមាហរណកម្មភាពការណ៍ហ្នឹងន៎ ហើយបន្តលទ្ធភាពឲ្យយើងរកស៊ីចិញ្ចឹមជីវិតបានពេញទី ទាំងធ្វើចំការក្តី ទាំងជួយដូរក្តី ។ ពិសេស យើងបានរស់នៅជួបជុំបងប្អូនកូនចៅ អត់មានការបែកបាក់គ្នាទេ ។ យើងរស់នៅសុខដុមរម្យនាជាមួយគ្នា ហើយយើងមានពេលវេលាគ្រប់គ្រាន់ក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិត ។ តាំងពីពេលនោះមក យើងឃើញជីវភាពរស់នៅរបស់ប្រជាជនយើងមានការរីកចំរើនច្រើន បើប្រៀបធៀបនៅក្នុងសង្គ្រាមគឺខុសគ្នាឆ្ងាយ ។ ក្រោយផ្តាច់ខ្លួនប៉ុន្មានឆ្នាំ យើងឃើញស្រុកម៉ាឡៃក្លាយជាស្រុកដែលពេញលក្ខណៈ ហើយមានការអភិវឌ្ឍន៍លឿន ។ ពិតមែនតែផ្លូវថ្នល់រៀបរយល្អ តែយើងអាចប្រើប្រាស់បាន ខែប្រាំងយើងអាចប្រើប្រាស់បាន ។

ប៊ុនថន ៖ តើពូធ្វើចំការទេ?

ណែត ៖ ធ្វើ ។

ប៊ុនថន ៖ ប៉ុន្មាន?

ណែត ៖ ខ្ញុំធ្វើបានពាហិកតា ។ ខ្ញុំដាំដំឡូងអត់កើត ។ សណ្តែកសៀងខូច សណ្តែកបាយខូច ។ ភ្លៀងជ្រាំ រលួយអស់ ។

ប៊ុនថន ៖ តើពូស្រុកកំណើតនៅណា?

ណែត ៖ នៅស្រុកសម្បូរណ៍ ខេត្តក្រចេះ ។

ប៊ុនថន ៖ ភូមិអ្វី?

ណែត ៖ ភូមិកែងប្រាសាទ ឃុំសម្បូរណ៍ ។ ស្គាល់ទេ!

ប៊ុនថន ៖ ខ្ញុំទៅ តែស្រុកសម្បូរណ៍មិនដែលទៅដល់ ។ ខ្ញុំទៅក្រចេះតាមឆ្នេ និងព្រែកប្រសព្វ ។

ណែត ៖ នៅលើទៀត នៅជាប់ភូមិខ្ញុំ ភូមិជីទាវ ម៉ែន សំអន នៅជាប់គ្នា ។ ភូមិ ម៉ែន សំអន នៅជាប់វត្តសសរ១០០ ហើយខ្ញុំនៅខាងត្បូងវត្ត ។

ប៊ុនថន ៖ តើពូរៀនសូត្រនៅទីនោះ?

ណែត ៖ បាទ ។ ភូមិកំណើតកើតជានៅទីនោះ រៀននៅទីនោះ ។

ប៊ុនថន ៖ ពូមានបងប្អូនប៉ុន្មាននាក់?

ណែត ៖ ខ្ញុំមានបងប្អូន៨នាក់ ។ សព្វថ្ងៃនៅសល់៣នាក់ ខ្ញុំកូនពៅ ។ បងបន្ទស់បាត់ខ្លួនឆ្នាំ១៩៦៩ ហើយនៅពីរនាក់ នៅផ្ទះស្រុកកំណើត ។

ប៊ុនថន :　ពូដែលទៅលេងគាត់ទេ?

ណៃគ :　ឆ្នាំ២០០២ ខ្ញុំទៅលេងម្តង ។

ប៊ុនថន :　ចុះគាត់ដែលមកលេងនៅទីនេះទេ?

ណៃគ :　មក ក្មួយៗមកលេង ។

ប៊ុនថន :　ឪពុកម្តាយពូនៅរស់ទេ?

ណៃគ :　ខូចអស់ហើយ នៅសល់តែបងគាត់ ។

ប៊ុនថន :　ពូមករៀននៅក្រចេះ ឬក៏នៅស្រុក?

ណៃគ :　ខ្ញុំមករៀននៅក្រចេះ ។ សម្បូរមានតែថ្នាក់បឋម ពេលរៀនអនុត្រូវមកខេត្ត ។

ប៊ុនថន :　ពូរៀនយូរឆ្នាំទេ?

ណៃគ :　ខ្ញុំបានមួយឆ្នាំរដ្ឋប្រហារ ។

ប៊ុនថន :　រៀបដល់ថ្នាក់ទីប៉ុន្មាន?

ណៃគ :　ថ្នាក់ទី៦ជំនាក់នោះ ។ ថ្នាក់ទី៧ នៅបឋមសិក្សា ។ ថ្នាក់ទី៦ អនុ ។

ប៊ុនថន :　ឈប់រៀប ពូត្រឡប់ទៅណា?

ណៃគ :　ឆ្នាំ៧០ ឈប់រៀន ខ្ញុំទៅផ្ទះ ។ ដល់ឆ្នាំ៧១ ខែ៦-៧ ខ្ញុំចូលបដិវត្តន៍ ។

ប៊ុនថន :　ចូលនៅក្នុងភូមិ?

ណៃគ :　អត់នៅក្នុងភូមិទេ ។ ខ្ញុំចូលមកនៅមន្ទីរស្រុក ។ ភារកិច្ចខ្ញុំគឺនៅហាត់រៀនសិល្បៈ ដើរលេង ឃោសនា ប្រមូលកម្លាំងប្រជាជនតាមភូមិ គ្រប់ភូមិក្នុងស្រុក ។

ប៊ុនថន :　ពូហាត់យូរទេ?

ណៃគ :　ខ្ញុំហាត់បីខែ ដើរលេងបីខែ ។ បីខែនោះ ម៉ាស្រុកសម្បូរណ៍នោះ ខ្ញុំដើរលេងគ្រប់ភូមិទាំងអស់ មិនឲ្យដល់ទេ ។ តាមកោះនៅក្នុងទន្លេ តាមភូមិជនជាតិ នៅតាមព្រៃ ដូចជា ស្រែជាស ជនជាតិព្នង ជនជាតិក្រោល ក្រឹងអីហ្នឹង ។ ដើរលេងអស់ ហើយខ្ញុំបានផ្លាស់ភារកិច្ចមកនៅមជ្ឈិម ។ នៅចុង៧១ ខែ១២ ខែរងារ ខ្ញុំផ្លាស់មក ព្រោះខែ៧ខ្ញុំចូល ។ ខែ១២ ឆ្នាំ៧១ ខ្ញុំចុះមកមជ្ឈិម ។

ប៊ុនថន :　តើហាត់សម្តែង ឬហាត់ល្ខោននិយាយ ល្ខោនបាសាក់ ឬហាត់អ្វី?

ណៃគ :　ខ្ញុំខាងសម្តែង ខាងកាយវិការ ។ មានក្រុមគេ គេខាងល្ខោនបាសាក់ ខាងយីកេ ។ ប៉ុនម្តែងរួមជាមួយគ្នា ជួនកាលដើរតួជាទាហាន ។

ប៊ុនថន :　នៅចេះចាំទេ?

ណែត : អត់ទេ ភ្លេចអស់ហើយ ។

ប៊ុនថន : តើមួយក្រុមប៉ុន្មាននាក់?

ណែត : ច្រើនណាស់ ។ ដូចជា៣០នាក់ បែកគ្នាអស់ហើយ ខ្លះស្លាប់ ។

ប៊ុនថន : កាលនោះពូអាយុប៉ុន្មាន?

ណែត : អាយុ១៦-១៧ហើយ ។

ប៊ុនថន : ជំទង់?

ណែត : បាទ ។

ប៊ុនថន : ពូនៅសិល្បៈបានមួយឆ្នាំទេ?

ណែត : ដូចជាមិនបានទេ ព្រោះខ្ញុំចូលខែ៧ ឆ្នាំ១៩៧១ ។ ចូលទៅនៅក្នុងអង្គភាពសិល្បៈហ្នឹង រហូតដល់ខែ១២ ឆ្នាំ៧១ហ្នឹង ខ្ញុំត្រូវបានអង្គការជ្រើសរើសឲ្យមកធ្វើការងារបច្ចេកទេសនៅមជ្ឈិម ។

ប៊ុនថន : តើធ្វើនៅខេត្តក្រចេះ?

ណែត : ទេ នៅខេត្តកំពង់ចាម ។

ប៊ុនថន : គេហៅមន្ទីរមជ្ឈិម?

ណែត : បាទ ប៉ុន្តែភ្លេចលេខហើយ ។ វាមានស៩១, ប១៧-១៦ ។ ស៩១ កន្លែងនាំសារ ។ ប១៧ កន្លែងកសិកម្ម ដាំដុះ ។ ប១៦ កន្លែងកសិកម្មដែរ ដាំដុះ បង្កបង្កើនផល ដើម្បីឧត្ថម្ភទៅមន្ទីរធំ សាខារបស់គេ ។

ប៊ុនថន : មន្ទីរនៅស្រុកអ្វី?

ណែត : កាលនោះដូចជានៅស្រុកស្ទឹងត្រង់ ម្តុំបឹងកេត ។

ប៊ុនថន : ចំការកៅស៊ូ?

ណែត : បាទ ។

ប៊ុនថន : ពូធ្វើអ្វីនៅមន្ទីរ?

ណែត : រត់សារ ។ ជិះកង់នាំសារ នាំសំបុត្រ ។

ប៊ុនថន : នាំទៅខាងណា?

ណែត : នាំមកតាមភូមិភាគ ។ យើងមិននៅថ្នាក់មជ្ឈិម កណ្តាល យើងរត់សារមិនមកភូមិភាគ ឬជូនកាលមកតំបន់ស្វយ័ត ។ ព្រះវិហារ ជាតំបន់ស្វយ័តមួយដែលគ្រប់គ្រងផ្ទាល់ដោយមជ្ឈិម ។ អីចឹងអត់ឆ្លងកាត់ភូមិភាគទេ រត់សារត្រូវមកតំបន់ស្វយ័ត ។ ឯភូមិភាគ៣០៤

មានភូមិភាគបូព៌ា អ៊ីចឹងខ្ញុំរត់សារមកភូមិភាគ៣០៤ មន្ទីរភូមិភាគ ។ មិនមែនយកសារមកឲ្យមេភូមិភាគផ្ទាល់ទេ គឺឲ្យមន្ទីរគេ យកទៅចាត់ចែងឲ្យមេភូមិភាគគេ ។ ទៅបូព៌ាក៏អ៊ីចឹងដែរ ហើយនឹងមកសមរភូមិ ។ មកព្រែកក្ដាម ប៉ុនកាលនោះអត់ទាន់មកដល់ព្រែកក្ដាមទេ មកផ្លូវ បាធាយ ព្រោះព្រែកក្ដាមកំពុងវាយគ្នាខ្លាំង ។ ប៉ុនខ្ញុំឆ្លងកាត់មកផ្លូវបាធាយ ខ្ញុំជិះកង់ឆ្លងកាត់វាលសោះខ្យល់ វាលតាំងគោក ទំរាំជិះកង់ឆ្លងកាត់វាលនេះខ្ញុំចង់ដាច់ចង់រស់ ព្រោះយន្តហោះនៅចាំត្រង់ហ្នឹង វាចាំមើលយើងឆ្លង ។

ប៊ុនថន : ជិះកង់មកចម្ងាយផ្លូវ៧០-៨០គីឡូ ពូប្រើរយៈពេលប៉ុន្មាន?

ណែត : បាទកាលនោះឆ្ងាយណាស់ ។ ជិះកង់ដេកផ្លូវមួយយប់ដល់ ព្រលឹមឡើងទៅវិញ ។ បើផ្លូវព្រៃយើងជិះសេះ ឡើងពីស្ទឹងត្រង់ទៅខាងក្រយា ដងក្ដា ទៅព្រះវិហារ យើងជិះសេះល្អជាង ។

ប៊ុនថន : ទៅព្រះវិហារកាន់តែឆ្ងាយ?

ណែត : ឆ្ងាយ ប៉ុនយើងមានបណ្ដាញ ។ យើងមានស្នាក់ដូចថាមជ្ឈិមដែរ ចេញពីស្ទឹងត្រង់ទៅក្រយា ដងក្ដា ចេញពីក្រយា ដងក្ដាមានមន្ទីរមជ្ឈិមមួយ ហើយគេបន្តយកទៅដាក់ត្រង់ណា តទៅទៀតបានដល់ ។ បើយើងចេញពីមជ្ឈិម ស្ទឹងត្រង់ឆ្ងាយ ។

ប៊ុនថន : ពូនៅមន្ទីរមជ្ឈិមរហូតដល់បែក ឬប្ដូរទៅខាងណាទៀត?

ណែត : ខ្ញុំនៅសាខាទេ មិនមែននៅកៀកគល់នឹម ស្គាល់ប្រវត្តិអ្នកដឹកនាំអត់ច្បាស់ទេ ។ ខ្ញុំនៅសាខារហូតដល់ដើម៧៥ ខ្ញុំផ្លាស់ពីហ្នឹង វិកិលមកនៅភ្នំអដ្ឋរស្ស ឆ្លងព្រែកក្ដាមមកនៅអដ្ឋរស្ស ភ្នំព្រះរាជទ្រព្យ ។ ដល់ពេលរំដោះភ្នំពេញគ្រីបបានខ្ញុំចូល ។ អ៊ីចឹងបានន័យថាពេលកំពុងវាយគ្នាខ្លាំង ខ្ញុំចូលមកនៅត្រង់នឹងហើយ ។

ប៊ុនថន : ពូមកនៅមន្ទីរដដែល?

ណែត : មន្ទីរមជ្ឈិមដដែល ចេះតែវិកិលមកកៀកភ្នំពេញ ។

ប៊ុនថន : មន្ទីរនេះនៅគ្នាច្រើន ហើយផ្នែកខុសគ្នា?

ណែត : ច្រើន ហើយខុសគ្នា ។

ប៊ុនថន : មានផ្នែកអ្វីខ្លះ?

ណែត : ផ្នែកមិនមានការងារអីសំខាន់ទេ ។ ការងារមានតែការងារដឹកជញ្ជូន ហើយនាំសារ ការងារសមរភូមិមានតែប៉ុណ្ណឹង ហើយនឹងការងារបង្កបង្កើនផល ដឹកជញ្ជូន ហើយនឹងនាំសារ ។

ប៊ុនថន : តើមន្ទីរគណៈជម្មិមធំ មានបែងចែកជាប៉ុន្មានសាខា?

ណៃគ : ខ្ញុំក្តាប់មិនដុំ ។ ខ្ញុំនៅសាខាជាមន្ទីរនាំសារ មិនមែននីរសារការពារ ជាអង្គរក្សទេ ។ នាំសារ នាំសំបុត្រ អីចឹងវាទៅឆ្ងាយបន្តិចដែរ ។ ខ្ញុំក្តាប់មិនដុំថា ក្នុងសាខារបស់មជ្ឈមមានការងារ អីខ្លះ ខ្ញុំអត់សូវដឹងដែរ ព្រោះការងារគេច្រើនដែរ ។ ខ្ញុំដឹងតែការងារខ្ញុំគឺនាំសារ ហើយនឹង បង្កើនផល ។

ប៊ុនថន : ពូមានម៉ូតូទេ?

ណៃគ : អត់ទេ យន្តហោះបាញ់ងាប់ ។

ប៊ុនថន : ប៉ុន្មាននាក់ពេលយកទៅម្តង?

ណៃគ : ភាគច្រើនទៅម្នាក់ឯង បើយ៉ាងច្រើនបានពីរនាក់ ។ ប៉ុនគេចែកមុខសញ្ញាគ្នា ក្នុងម៉ាមន្ទីរ នោះវាមានស្រី មានប្រុស ហើយមានកម្លាំងមួយចំនួននៅបង្កបង្កើនផលជាមួយស្រីៗ ។ គេជ្រើសរើសមនុស្សដែលមានដៃជើងរឹងមាំ កាយសម្បទារឹងមាំឲ្យនាំសារ ពេលទំនេរគឺ ជួយបង្កបង្កើនផលគេ ប៉ុន្តែពេលមានសារមកអ្នកឯងត្រូវក្តាប់មុខសញ្ញាអ្នកឯងឲ្យបាន ។ ដូចខ្ញុំកាលនោះគឺចុះមកក្រោម ចេញពីស្ទឹងត្រង់ចុះមកក្រោម ពីដំបូងចុះមកស្ពឺ ស្រែវាល ក្រោយមក តំបន់រំដោះកាន់តែធំ ចុះមកស្ពោមានជ័យ តាំងគោក ។ ដល់តំបន់កាន់តែរីក ចុះមកដល់ផ្លូវ បាធាយ អាហ្នឹងមុខសញ្ញាខ្ញុំ ។ ដល់រីកធំមែនទែន មកដល់ព្រែកក្តាម ហើយមកដល់អដ្ឋរស្ស ហើយមុខសញ្ញាគេផ្សេង គេទៅកំពង់ធំ ។ ទៅក្រយា ដងក្តា ឡើង ទៅកំពង់ធំ ។ មុខសញ្ញាមួយទៀត គេទៅព្រះវិហារ ហើយមុខសញ្ញាមួយទៀត គេឆ្លង ទន្លេមកក្រចេះ មកតំបន់ស្វយ័ត៥០៥ ខេត្តក្រចេះនេះ ។ មុខសញ្ញាមួយទៀត គេមក បូព៌ា ខាង សោ ភីម ចែកផ្លូវគ្នា ។ អីចឹងបានថា ខ្ញុំរត់សារមែន ប៉ុន្តែអត់បានទៅមុខ សញ្ញាគេទេ មកតែមុខសញ្ញាខ្លួនឯង ។

ប៊ុនថន : ពូមកដល់អដ្ឋរស្សឆ្នាំប៉ុន្មាន?

ណៃគ : ៧៥ ។

ប៊ុនថន : ពូនៅបានរយៈពេលប៉ុន្មាន?

ណៃគ : នៅកន្លះខែ ។

ប៊ុនថន : បែកហើយ ពូមកនៅខាងណា?

ណៃគ : ចូលមកដល់ដំបូងនៅក្នុងវាំង ។ ៧៥ ខ្ញុំនៅក្នុងវាំង នៅរៀបចំបោស ប្រាស សម្អាត់ក្នុង វាំង និងរៀបចំរត់តុបម្រើព្រះករុណា ។ ឆ្នាំ៧៦ បានខ្ញុំចេញពីវាំងទៅនៅក្រសួងការ រទេស នៅធ្វើការនៅផ្ទះវិមានរដ្ឋមួយនៅមាត់ទន្លេ ។

ប៊ុនថន : សន្និសីទចតុមុខ ឬក៏?

ណែត : វិមានរដ្ឋនៅក្បាលស្ពានជ្រោយចង្វារ វិមានរដ្ឋាភិបាលមួយធំណាស់ ផ្ទះចាស់ ។ ស្គាល់ទេ!

ប៊ុនថន : អូ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា?

ណែត : បាទ កាលនោះក្រសួងការបរទេស គេអ្នកគ្រប់គ្រង សម្រាប់ទទួលប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ។ កាលនោះគេហៅ គេដាក់ផ្ទះលេខ១ ប៉ុនឯកឧត្តម គាត ឈន់ ស្គាល់ច្បាស់ហើយ ។ ខ្ញុំនៅនោះបានប៉ុន្មានថ្ងៃ បានខ្ញុំមកនៅខាងលិចវត្តភ្នំ គេហៅផ្ទះលេខពីរ អាផ្ទះបារាំង ទល់មុខលីសេដេកាត ។

ប៊ុនថន : ឥឡូវគេហៅក្រសួង...?

ណែត : ទេ ឥឡូវនៅអូរតែល ។

ប៊ុនថន : ឡឺរ៉ូយ៉ាល់?

ណែត : បាទ ប៉ុនបាត់រូបសំណាកដើមអស់ហើយ ឥឡូវគេកែសោភណ្ឌភាព ខ្ញុំមើលលែងស្គាល់ហើយ ។

ប៊ុនថន : កាលមុនគេដាក់ឡឺភ្នំ?

ណែត : បាទ ។

ប៊ុនថន : លោកពូបែកភ្នំមកនៅក្នុងវាំង?

ណែត : បាទ បំរើព្រះករុណា ចេញពីព្រះករុណាមក ខ្ញុំមកនៅក្រសួងការបរទេស ។ ក្រសួងការបរទេសវាមានពីរផ្ទះហ្នឹង ផ្ទះមាត់ទន្លេមួយ ឡឺរ៉ូយ៉ាល់ខាងលិចវត្តភ្នំមួយ ។

ប៊ុនថន : គ្នាច្រើនទេ?

ណែត : ច្រើនដែរ ប្រហែល៥០នាក់ ព្រោះតែផ្ទះហ្នឹងមួយ ឡឺរ៉ូយ៉ាល់មួយគឺបំរើភ្ញៀវទូទាំងប្រទេស ។ អីចឹងមនុស្សច្រើនណាស់ ពួកក្មេងៗមួយសារខ្ញុំ ទាំងស្រីទាំងប្រុស ។ ទាំងអ្នកដាំបាយ ដាំស្ល បំរើ ទាំងស្រីទាំងប្រុស ព្រោះចែកមុខសញ្ញាទៅសៀមរាប កំពង់សោម គាកែវ ទៅតំបន់ទេសចរណ៍ ព្រោះភ្ញៀវរាល់ថ្ងៃ ទៅតាមភ្ញៀវជាប់ ។ មិនមែនឥឡូវទេ បើដូចឥឡូវមិនទៅធ្វើកើតទេ ពួកខ្ញុំនោះ ព្រោះកម្លាំង៥០នាក់នោះ គឺចេញដើរតាមភ្ញៀវរាល់ថ្ងៃ ។

ប៊ុនថន : ភាគច្រើនគេទៅទស្សនកិច្ចនៅណា?

ណែត : នៅសៀមរាប អង្គរវត្ត ហើយកំពង់សោម និងទៅមើលតាមការដ្ឋាន ។

ប៊ុនថន : ពូដើរសព្វនៅកន្លែងផ្សេងៗ?

ណែត ៖ ដើរច្រើនដែរ ។

ប៊ុនថន ៖ មានអ្នកបកប្រែ និងមានបើកឡាន?

ណែត ៖ ក្រុមបើកឡានគេមាន ហើយបកប្រែគេមានក្រុមគេ ។ នៅក្នុងក្រសួង គេមានក្រុមបកប្រែ ដូចភាសាចិន អង់គ្លេស ។

ប៊ុនថន ៖ ពូនៅក្រុមខាងណា?

ណែត ៖ ខ្ញុំនៅខាងបំរើ ។ ខាងបាយទឹក ។ រៀបចាន រៀបឆ្នាំ បាយទឹក ភេជ្ជៈ ។

ប៊ុនថន ៖ ទៅដល់ខេត្ត មានគេបន្តទៀត?

ណែត ៖ មានគេទទួលបន្ត ប៉ុន្តែយើងធានាសន្តិសុខម្ហូបអាហារ ភ្ញៀវ យើងរៀបបាយ រៀបទឹក រៀបចាន រៀបរបៀបម៉េច ។ ភ្ញៀវឋានៈណារៀបម៉េច ទាំងកន្លែងដេក ។

ប៊ុនថន ៖ តែអ្នកបំរើភាគច្រើនគេរើសស្រី?

ណែត ៖ ជំនាន់ខ្មែរក្រហមប្រុសក៏បំរើបាន ស្រីក៏បំរើបានដែរ ។ លើកបាយ លើកម្ហូបតែប្រុសៗ ។

ប៊ុនថន ៖ ពូមានរៀនពីពិធីការលើកម្ហូបទេ?

ណែត ៖ ពិធីការរៀន ។ ភ្ញៀវអឺរ៉ុបធ្វើម្ហូបរបៀបម៉េច ត្រូវលើករបៀបម៉េច របៀបលើកម្ហូប លើកបាយ ។ ហុចពីខាងណាមុន ខាងណាក្រោយ រៀបតាមពិធីការទាំងអស់ ។

ប៊ុនថន ៖ បង្រៀនដល់ពូដែរ?

ណែត ៖ ចុះសុទ្ធតែអ្នកចេះ ។ ចុះ គាត ឈន់ គាត់ធ្លាប់ដើរបរទេសសឹកអស់ហើយ ។

ប៊ុនថន ៖ គាត់បង្រៀនពូ?

ណែត ៖ បាទ គណៈប្រតិភូណាធំ ណាតូច ។ យើងជូនទឹកគេ ជូនអ្នកណាមុនហ្នឹងជាពិធីការ ។

ប៊ុនថន ៖ ក្រោយពេលពូចេញពីវាំង?

ណែត ៖ បាទ ។

ប៊ុនថន ៖ ពូនៅបំរើព្រះករុណា?

ណែត ៖ បាទ កាលនោះនៅរៀបបាយ ។

ប៊ុនថន ៖ ច្រើននាក់ទេ?

ណែត ៖ នៅគ្នា៥-៦នាក់ ។ ៤-៥នាក់ ។ ក្រោយមកនៅតែ៣នាក់ ។ កាលជំនាន់ខ្ញុំនៅ៤-១០ នាក់ដែរ ទាំងអ្នកបោសសម្អាត់ ទាំងអ្នករៀបបាយ រៀបទឹក ដាំបាយ ស្ល ។

ប៊ុនថន ៖ មានអ្នកធ្វើម្ហូបផ្សេង?

ណែត ៖ ផ្សេងមាន៣-៤នាក់ ។

ប៊ុនថន ៖ ប្រុសតែពូម្នាក់?

ណែត ៖ ច្រើន អ្នករៀបបាយ រៀបចាន ជូតផ្ទះ ។

ប៊ុនថន ៖ ចុះស្រីៗ?

ណែត ៖ ដាំស្ល ។

ប៊ុនថន ៖ ព្រះករុណាពិសារម្ហូបធម្មតា?

ណែត ៖ យើងធ្វើតាមម្ហូបលោកកុម្មង់ លោកចង់ស្លរកកូរ ស្លរកកូរឲ្យលោកទៅ ។ ជួនកាលភីលាង លោកគគោក លោកច្រើនហូបម្ហូបស្រែច្រើន ។ កាលខ្ញុំនៅហូបម្ហូបស្រែច្រើន លោកចង់ភាគច្រើនលោកចង់ពស់ពិស ។ ពស់ចាប់មកទាំងទ្រុងៗយកពីជនបទ ។

ប៊ុនថន ៖ ព្រះអង្គនៅជុំជាមួយអ្នកម្នាង ម៉ូនិក និងកូនចៅច្រើនទេ?

ណែត ៖ កាលនោះច្រើនដែរ តែខ្ញុំស្គាល់មិនអស់ មិនដឹងនរណាទេ ។ ជុំច្រើនម៉ាត្រកូលគាត់ច្រើន ។

ប៊ុនថន ៖ ព្រះករុណារាល់ថ្ងៃ សីហមុនី នៅជាមួយដែរ?

ណែត ៖ ខ្ញុំមិនច្បាស់ដែរ នរិន្ទ្រពង្ស សីហមុនី នៅហ្នឹងដែរ ។

ប៊ុនថន ៖ ស្រដៀងគ្នា?

ណែត ៖ ខ្ញុំចាំច្បាស់ នរិន្ទ្រពង្ស ទៅនៅបារាំង កាលនោះចេញពីម៉ាឡៃទៅ ។ ជំនាន់៨១-៨២ ចូលមកនេះ មកហ្នឹងបីដង មកទួលគ្រាប់ លីគ្រាប់ទៅសមរភូមិ ។ ដក់បារីស៊ើកសង្កែ បាត់ពីហ្នឹងមករហូត ។

ប៊ុនថន ៖ ពូជួបទេ?

ណែត ៖ បាទ គាត់មក ។

ប៊ុនថន ៖ គាត់ស្នាក់នៅហ្នឹង?

ណែត ៖ នៅហ្នឹង ។

ប៊ុនថន ៖ នៅសារគាំង?

ណែត ៖ នៅមាត់អូរត្រង់នោះ មិនមែននៅសារគាំងទេ អានេះរបស់ព្រះករុណា សម្ដេចតា ។ គាត់មកមុនសម្ដេចតាទៀត ឆ្នាំ៧៩ ឆ្នាំ៨០ មកលីគ្រាប់ ។

ប៊ុនថន ៖ នៅក្មេង?

ណែត ៖ ក្មេង នរិន្ទ្រពង្ស ។ ក្រោយមក បានឮថាទៅបារាំងវិញ ។

ប៊ុនថន ៖ តើព្រះករុណាដែលនិយាយលេងជាមួយពូទេ?

ណែត ៖ និយាយលេងធម្មតា លោកហៅកូន ក្មួយ ប៉ុនយើងអត់ចេះនិយាយភាសា ។ ចេះតែពាក្យបន្ទាត់ព្រះករុណាថ្ងៃវិសេស ពាក្យបាទៗ មិនដែលនិយាយ ។ យើងអត់ចេះភាសាលោក ។

ប៊ុនថន ៖ ពូនៅក្នុងវាំងផ្ទាល់ ឬមានកន្លែងផ្សេងនៅក្រៅ?

ណែត ៖ នៅក្នុងរបងវាំង ប៉ុនមានផ្ទះតូចនៅក្រៅ ផ្ទះសម្រាប់អ្នកបម្រើនៅក្រៅ ។ មិនមែននៅក្នុងប្រាសាទទេ ។

ប៊ុនថន ៖ នៅក្នុងរបបតែកន្លែងផ្សេង?

ណែត ៖ បាទ នៅក្នុងរបង តែមានផ្ទះតូច ដូចផ្ទះបាយ ព្រោះយើងការការពារ យាមផង ។ យើងមិនបានទៅដេកនៅក្នុងប្រាសាទទេ ។

ប៊ុនថន ៖ គេបើកឲ្យចូលមើលប្រាសាទទេ?

ណែត ៖ កាលនោះវាថ្មីពេក ពេលវេលាវាខ្លី ដូចមិនទាន់មានទេ ។ ១៩៧៥ ហើយ ខ្ញុំចេញចង់ផុត៧៥ ។

ប៊ុនថន ៖ នៅវាំងដល់មួយឆ្នាំទេ?

ណែត ៖ មិនដល់ទេ ចុង៧៥ ខ្ញុំចេញហើយ ។

ប៊ុនថន ៖ ចេញមកពីនោះ មកក្រសួងការបទេស?

ណែត ៖ បាទ ផ្ទះលេខមួយ លេខ២ ។

ប៊ុនថន ៖ ពូគង់នៅទីនោះដែរ?

ណែត ៖ សួង ស៊ីគឿន!

ប៊ុនថន ៖ បាទ ។

ណែត ៖ គាត់អ្នកបកប្រែ គាត់នៅលំដាប់ខាងលើ ។ ខាងសរសេរ និងបកប្រែភាសា ។ គង់ បុតធ្លាប់ជួបគាត់ទេ!

ប៊ុនថន ៖ អត់ទេ ។ ខ្ញុំធ្លាប់មើលឯកសារ និងដឹងធ្វើការនៅក្រសួងការបរទេស ។

ណែត ៖ សួង ស៊ីគឿន គាត់ធ្វើការជាមួយ គាត ឈន់ ។

ប៊ុនថន ៖ ពូនៅក្រសួងការបរទេសបានយូរទេ?

ណែត ៖ នៅដល់ឆ្នាំ៧៧ ខែ៨ ខ្ញុំទៅនៅសាខាមួយទៀតរបស់ក្រសួងការបរទេស កន្លែងបង្កើនផល ។ ឈប់នៅបំរើភ្ញៀវហើយ ខ្ញុំនៅកន្លែងបង្ករបង្កើនផល រហូតដល់យួនចូល ។

ប៊ុនថន ៖ តើមានឈ្មោះគេដាក់?

ណែត ៖ ស្ទឹងកន្លែងហ្នឹង ដូចជានៅតាខ្មៅ ។ កន្លែងអនុវិទ្យាល័យពីរជាប់គ្នានៅកណ្ដាលបឹង ក្រោយតាខ្មៅ ។

ប៊ុនថន ៖ ឥឡូវអនុវិទ្យាល័យសេរីភាព?

ណែត ៖ អត់ស្គាល់ទេ ឥឡូវខ្ញុំទៅមើលលែងយល់អស់ហើយ ។ ទៅឃើញគេចាក់ដីពេញអស់ហើយ ។ ទៅឃើញវិទ្យាល័យនឹងនៅដដែល នៅកណ្ដាលស្រែ ។

ប៊ុនថន ៖ រហូតដល់៧៩?

ណែត ៖ បាទរហូតដល់ឆ្នាំ៧៩ ចេញពីហ្នឹង ។ ម៉ាមន្ទីរខ្ញុំមកលិចទាំងអស់ មកជាស៊ីវិល ជាប្រជាជនដល់មកដល់អមលាំងបានជួបមេៗ ។ ចាប់ផ្ដើមគេបំពាក់កាំភ្លើង ចេះតែថយមក ថយបណ្ដើរ ទប់បណ្ដើរៗ ។ ថយត្រង់គេដេញ ដាក់ទប់មួយប្រាវទៅ ចេះតែថយៗមក រហូតដល់ព្រំដែន ។

ប៊ុនថន ៖ មានបែងចែកជាកងវរទេ?

ណែត ៖ មាន ។

ប៊ុនថន ៖ ពូនៅកងវរណា?

ណែត ៖ ដូចភ្លេចអស់ហើយ កាលនោះពួកក្រសួងការបរទេសនោះ គេរៀបចំអ្នកដែលចេញពីភ្នំពេញមក ។ ប្រមូលគ្នាបានច្រើន ម៉ាវរសេនាតូច បីបួនរយនាក់ ហើយក្រោយមកបានលាយជាមួយខាងរោងចក្រ ខាងអគ្គភាពណាដែលបែកបាកខ្ចាតខ្ចាយរកមេរកកើយមិនឃើញ ក៏ប្រមូលបានមួយកងពល នាំគ្នាមកព្រំដែនមក ។

ប៊ុនថន ៖ កងពលលេខប៉ុន្មាន?

ណែត ៖ កាលនោះមិនទាន់មានលេខទេ ។

ប៊ុនថន ៖ មានអ្នកគ្រប់គ្រងទេ?

ណែត ៖ មិនទាន់ច្បាស់ទេ មិនទាន់រៀបរយទេ ។ ពូចៀម គាត់គ្រប់គ្រង ចេះតែនាំមក ។

ប៊ុនថន ៖ ចម្រុះ?

ណែត ៖ បាទ!

ប៊ុនថន ៖ គេមានរៀបចំកម្លាំងតាមក្រសួង?

ណែត ៖ ជាទិសដៅអញ្ចឹង ប៉ុន្តែវាបែកបាក់គ្នាអស់ ។ ក្រសួងមួយៗមិនជុំមេក្រសួងទេ ។ មេក្រសួងខ្លះមក ខ្លះក៏អត់មក ។ មកតែកម្លាំង កម្លាំងខ្លះក៏មក ខ្លះក៏អត់មក អីចឹងវាដាច់ដោចរបាត់របាយ ។ យើងមកប្រមូលនៅព្រំដែននេះ ។

ប៊ុនថន ៖ ពូនៅកន្លែងគ្រប់គ្រងចាស់?

ណែត ៖ ខ្ញុំនៅមេចាស់ដដែល ។

ប៊ុនថន ៖ តា អៀង សារី?

ណែត ៖ បាទ ។ មេចាស់ ហើយរងពីគាត់មក មាន ពូចៀម និង ហុង ។ កាលនោះគាត់ស៊ីវិល ដល់ធ្វើទាហានគាត់នៅតែមេរហូត ។

ប៊ុនថន ៖ ហុងនោះគាត់នៅក្រសួងការបរទេស?

ណែត ៖ បាទ ។

ប៊ុនថន ៖ កាលនោះគាត់ខាងអី?

ណែត ៖ តាមខ្ញុំចាំដូចជារដ្ឋលេខាធិការ បន្ទាប់ពី អៀង សារី ឃើញពុះឈ្មោះតែមួយ ព្រោះគាត់ជំនួសឲ្យ អៀង សារី ចរចារ ។ ឯបញ្ញាជនផ្សេងទៀតដូចមិនពុះឈ្មោះឋានៈជាស្អីទេ ខ្លះជាទីប្រឹក្សា ខ្លះជាជំនួយការឲ្យ អៀង សារី នៅក្រសួងការបរទេស ។

ប៊ុនថន ៖ កាលជំនួយការគាត់ច្រើនទេ?

ណែត ៖ ច្រើន គាត ឈន់ ហោ ណាំហុង សុទ្ធតែបញ្ញាជន ។ សួង ស៊ីគឿន ឡុង ណារិន ។

ប៊ុនថន ៖ កាលមកនោះ ឯកឧត្តម គាត ឈន់ និង ហោ ណាំហុង រត់មកជាមួយគ្នា?

ណែត ៖ គាត់ ឈន់ គាត់មកដល់ព្រំដែន ធ្វើការនៅព្រំដែន ទើបនឹងទៅ៩៣ ។ ពេលបោះឆ្នោតគាត់ទៅវិញ គាត់មកនៅនេះតាំងពី៧៩រហូត ។ ៨០ ៨៩ ពេលដែល ៨៦ ពេលដែលគេវាយមកអស់ដីអស់ទឹក នាំគ្នារត់ចូលទៅនៅដីគេនោះ គាត់ទៅនៅបារាំងទាំងប្រពន្ធកូន ។ ដល់ឆ្នាំ៩៣ គាត់ចូល ។

ប៊ុនថន ៖ ឯកឧត្តម ហោ ណាំហុង គាត់មកនឹងដែរ?

ណែត ៖ មកដែរ ។ មកដល់អន្លង់មៀននោះ ពូចៀម ឲ្យគាត់នៅគ្រប់គ្រងកម្លាំងប្រជាជន និងនារីប៉ុន្មានពាន់នាក់នៅនោះ ឲ្យគ្រប់នៅនោះសិន ចាំទំរាំកងទ័ពមករកទីកន្លែងហើយ កងទ័ពទៅយកវិញ ។ ដល់ពេលនេះ គេវាយបុកកាត់ពីក្រោយ ទាក់យក កៀរយកទៅអស់ទៅ ។

ប៊ុនថន ៖ កៀរទាំងនារី?

ណែត ៖ ទាំងអស់ រាប់ពាន់រាប់ម៉ឺននាក់ ។ កៀរយកទៅវិញ អន្លង់មីន ។

ប៊ុនថន ៖ នៅណា?

ណែត ៖ អន្លង់មីន នៅស្រុកសំឡូត ។

ប៊ុនថន ៖ ទៅតាំងពីនោះ?

ណែត ៖ បាទគាត់ទៅភ្នំពេញ ។ គាត់មានចំណេះវិជ្ជា គាត់ទៅរកកន្លែងការងារ គាត់ធ្លាប់ធ្វើការ ។

ប៊ុនថន ៖ ពូស្គាល់ គាត ឈន ច្បាស់ទេ?

ណែត ៖ កូនគាត់មកធ្វើការនៅនេះ ។ គាត រស្មី ។

ប៊ុនថន ៖ គាត់កាន់ខាងអី?

ណែត ៖ មានការងារ គាត់មកជួយគណបក្ស ជាមួយឯកឧត្តម សុន គន្ធរ ចុះមករាល់ខែ ។

ប៊ុនថន ៖ ស្រី?

ណែត ៖ ទេ ប្រុស ។ គាត ករណី បានស្រី ។

ប៊ុនថន ៖ គាត់ជាក្រុមការងារចុះជួយគណបក្ស ។ តើកូនៅស្គាល់ពូទេ ព្រោះពូអាយុជិត៦០?

ណែត ៖ បាទ កូនគាត់អាយុ៥១ហើយ ។

ប៊ុនថន ៖ ស្គាល់ពូទេ?

ណែត ៖ ស្គាល់ ។

ប៊ុនថន ៖ ពូទៅភ្នំពេញ ដែលទៅលេងគាត់ទេ?

ណែត ៖ អត់ទេ ។ គាត់មកលេងនៅនេះ ។

ប៊ុនថន ៖ គាត់នៅក្រចេះ?

ណែត ៖ នៅព្រែកប្រសព្វ ឆ្លង ។

ប៊ុនថន ៖ តើដឹបូងស្រីៗដែលមកដល់ទីនេះពុំទាន់មានគ្រួសារ?

ណែត ៖ អត់ទាន់មានទេ គឺថានៅលីវទាំងអស់ ។

ប៊ុនថន ៖ តើយ៉ាងម៉េចបានអត់មានគ្រួសារ?

ណែត ៖ ៩៩ភាគរយមានតែមួយទេ ។ ៩៩ភាគរយគឺអត់តែម្តង ។ សុទ្ធតែយុវជន យុវនារីកម្មាំងពេញៗមកទាំងអស់តែម្តង នឹងមិននិយាយពីប្រជាជនទេ ។ ប្រជាជននៅតាមសហករណ៍គាត់មានកូនមានចៅមក ជាកម្លាំងចេញពីក្រសួងមន្ទីរមក ។ កាលនោះម៉ាកងខ្ញុំ មានប្រពន្ធតែខ្ញុំមួយ ហើយ ខេង មន មីង ខេង ក្រុមប្រឹក្សាឃុំមួយ ហើយពូ ចៀម មួយ ហើយ ឈឹម ប៊ុននី មួយ ។ ហើយមនុស្សរាប់ពាន់នាក់ ហើយ សូ ហុង មួយ ក្រៅពីនោះនៅលីវទាំងអស់ ទាំងស្រីទាំងប្រុស ។

ប៊ុនថន ៖ ពូមានគ្រួសារឆ្នាំប៉ុន្មាន?

ណែត ៖ ៧៧ ។

ប៊ុនថន ៖ ពេលនោះពូនៅក្រសួងការបរទេស?

ណែត ៖ បាទ ។

ប៊ុនថន ៖ គ្រួសារពូនៅក្រសួងនេះដែរ?

ណែត ៖ នៅជាមួយគ្នា ។ គេដាំស្ល បម្រើ ។

ប៊ុនថន ៖ ឥឡូវកូនប៉ុន្មាននាក់?

ណែត ៖ ៦ ។

ប៊ុនថន ៖ កូនបងអាយុច្រើនដែរ?

ណែត ៖ ៣០ហើយ ។ មិនទាន់មានប្រពន្ធ ។

ប៊ុនថន ៖ អត់មានគ្រួសារទាំងអស់?

ណែត ៖ មានគ្រួសារពីនាក់ នៅ៤ ។ នៅអាបងនៅ មានតែប្អូន ហើយស្រីបីនៅ ។

ប៊ុនថន ៖ នៅរៀនខ្លះ?

ណែត ៖ រៀនបាត់ដំបងមួយ នៅនេះពីរស្រី ។ បងធ្វើគ្រូ អាមួយប្អូននោះមានប្រពន្ធនៅនោះ ហើយអាមួយធ្វើស្មៀនឃុំនោះ យកប្រពន្ធនៅឃុំបឹងបេង ហើយទៅនៅនោះ ។

ប៊ុនថន ៖ នៅរៀនខ្លះដែរ?

ណែត ៖ នៅរៀននៅសកលវិទ្យាល័យ ហើយអានេះទើបនឹងចប់ ។ អត់ប្រពន្ធ ។ កូនស្រី!

ប៊ុនថន ៖ បង?

ណែត ៖ វារៀននៅស្វាយ នៅបន្ទាយមានជ័យ ។

ប៊ុនថន ៖ ខាងនេះទៅរៀននៅបន្ទាយមានជ័យច្រើន?

ណែត ៖ ជិតផ្ទះស្រួល ។

ប៊ុនថន ៖ ខ្ញុំដូចជាអត់មានអីសួរលោកពូទៀតទេ ហើយអរគុណពូដែលផ្តល់ព័ត៌មានឲ្យ ។

**-ចប់-**